# មជ្ឈមណ្ឌលឯកសារកម្ពុជា

PTI0065

## សម្ភាសន៍ជាមួយឈ្មោះ ប្រាក់ សុខា ភេទប្រុស អាយុ៥៦ឆ្នាំ

## មុខងារជំនាន់ខ្មែរក្រហម "យោធា"

## ស្រុកកំណើតនៅភូមិព្រៃឈើទាលក្រោម ឃុំអន្លុងតាសោម ស្រុកត្រាំកក់ ខេត្តតាកែវ

## រស់នៅភូមិប្រម៉ោយ ឃុំប្រម៉ោយ ស្រុកវាលវែង ខេត្តពោធិ៍សាត់

## ថ្ងៃទី២១ ខែឧសភា ឆ្នាំ២០១១

## សម្ភាសន៍ដោយៈ សុខ វណ្ណៈ

## ០០:៥១:៥៨

## ២២ទំព័រ

វណ្ណៈៈ ចឹងថ្ងៃហ្នឹងថ្ងៃទី២១ខែ៥ឆ្នាំ២០១១ ។

សុខាៈ បាទ ។

វណ្ណៈៈ ខ្ញុំមកពីខាងអង្គការមជ្ឈមណ្ឌលឯកសារកម្ពុជា មកដល់ភូមិឃុំពូគឺចង់ដឹងពីប្រវត្តិទាក់ទងនិងស្រុកវាលវែង ហើយចង់ដឹងបងប្អូនយើងដែលធ្លាប់ឆ្លងកាត់ពីរបីជំនាន់មកជួបការលំបាកយ៉ាងម៉េចខ្លះហើយមានសុខទុកយ៉ាងម៉េចខ្លះ?

សុខាៈ បាទ ។

វណ្ណៈៈ ហើយពត៌មានខ្ញុំជាមួយពូហ្នឹង ខ្ញុំចង់យកទៅចងក្រងជាឯកសារប្រវត្តិសាស្រ្តពូមិនថាអីទេ យកទៅចងក្រងឲ្យក្មេងបានរៀនបានសូត្រអីដែរ?

សុខាៈ បាទ ។

វណ្ណៈៈ ចឹងជាដំបូងខ្ញុំចង់ស្គាល់ឈ្មោះពូ ពូឈ្មោះអីដែរ?

សុខាៈ ខ្ញុំឈ្មោះប្រាក់ សុខា ។

វណ្ណៈៈ ចឹងពូអាយុប៉ុន្មានហើយ?

សុខាៈ ខ្ញុំអាយុ៥៥ឆ្នាំ ។

វណ្ណៈៈ ប្រពន្ធពូឈ្មោះអីដែរ?

សុខាៈ ឈ្មោះ ព្រាប ផាត ។

វណ្ណៈៈ គាត់អាយុប៉ុន្មានហើយ?

សុខាៈ អាយុ៥៦ ។

វណ្ណៈៈ ពូមានកូនប៉ុន្មាននាក់?

សុខា៖ កូនមាន៥នាក់ ។

វណ្ណៈ៖ ស្រីប៉ុន្មាន?

សុខា៖ ស្រី២ ។

វណ្ណៈ៖ ឪពុកពូឈ្មោះអីដែរ?

សុខា៖ ប៉ាខ្ញុំឈ្មោះ ញ៉ែម ហ៊ាន ។

វណ្ណៈ៖ ចឹងម្តាយ?

សុខា៖ ម្តាយអែម ឃិន ។

វណ្ណៈ៖ ចឹងគាត់ទាំងពីរនៅរស់ដល់សព្វថ្ងៃដែលពូ?

សុខា៖ ប៉ាខ្ញុំគេយកទៅសម្លាប់ចោលកាលឆ្នាំ៧៣បាត់ហើយ ។

វណ្ណៈ៖ ចឹងសម្លាប់តាំងពីមុខខ្មែរក្រហមចូលម្ល៉េះ?

សុខា៖ ស្លាប់តាំងពីវើសម័យលន់ នល់ ។

វណ្ណៈ៖ ចឹងម្តាយ?

សុខា៖ ម្តាយនៅរស់ ។

វណ្ណៈ៖ ចឹងបងប្អូនបង្កើតពូ?

សុខា៖ មាន៥នាក់ ។

វណ្ណៈ៖ នៅរស់?

សុខា៖ នៅទាំងអស់ ។

វណ្ណៈ៖ ចឹងសព្វថ្ងៃគាត់រស់នៅស្រុកកំណើតឬមួយមករស់នៅជាយដែនដែរ?

សុខា៖ ប្អូនៗខ្ញុំមួយពៅនៅធ្វើទាហាននៅព្រះវិហារ ។

វណ្ណៈ៖ ចឹងស្រុកកំណើតពូនៅណា?

សុខា៖ នៅភូមិព្រៃឈើទាលក្រោម ។

វណ្ណៈ៖ ឃុំ?

សុខា៖ ឃុំអង្គតាសោម ស្រុកត្រាំកក់ ខេត្តតាកែវ ។

វណ្ណៈ៖ ឥឡូវពូនៅភូមិអី?

សុខា៖ ភូមិប្រម៉ោយ ឃុំប្រម៉ោយ ស្រុកវាលវែង ខេត្តពោធិសាត់ ។

វណ្ណៈ៖ សព្វថ្ងៃពូប្រកបមុខរបរអីដែរពូ?

សុខា៖ ធ្វើចំការ ។

វណ្ណៈ	ពូមានចំការច្រើនដែរ?

សុខាៈ	ចំការមានបីទៅបួនហិចតាហ្នឹង ។

វណ្ណៈ	ចឹងយើងអាចប្រកបមុនរបរចិញ្ចឹមជីវិតបាន?

សុខាៈ	បាទ ។

វណ្ណៈ	ចឹងកាលពូតូចពូរៀនដល់ថ្នាក់ណាដែរ?

សុខាៈ	កាលពីតូចរៀនត្រឹមថ្នាក់ទី៩ ។

វណ្ណៈ	ចឹងថ្នាក់ទី៩ចាស់?

សុខាៈ	បាទ ។

វណ្ណៈ	ហេតុអីបានជាពូឈប់រៀន?

សុខាៈ	ឈប់រៀនកាលហ្នឹងដោយសារថាស្រុកកើតសង្គ្រាមឆ្នាំ៧០មានខ្មែរក្រហមឈប់ទៅ ។

វណ្ណៈ	ចឹងដោយសារថាកើតសង្គ្រាមឆ្នាំ៧០?

សុខាៈ	បាទ ។

វណ្ណៈ	ចឹងឆ្នាំ៧០ពូឈប់រៀនហើយពូបន្តទៅធ្វើអីទៀត?

សុខាៈ	ឆ្នាំ៧០ខ្ញុំឈប់រៀន ឆ្នាំ៧១ខ្ញុំចេញពីភូមិមកនៅតំបន់រំដោះគេហៅតំបន់រំដោះមកធ្វើឈ្លបឃុំ មុនដំបូង ។

វណ្ណៈ	ចឹងកាលពូចេញពីភូមិនៅឆ្នាំ៧១ហ្នឹងចេញទាំងគ្រួសារតែម្តង?

សុខាៈ	បាទ! ចេញទាំងគ្រួសារជិតបន្ទាយទាហាន ជិតតំបន់ទាហានកាន់កាប់ជម្លៀសចេញមក ។

វណ្ណៈ	មកតំបន់រំដោះហ្នឹងនៅកន្លែងណា?

សុខាៈ	មកនៅភូមិទ្រវង់ ឃុំតាភេម ។

វណ្ណៈ	ស្រុកអីគេហ្នឹង?

សុខាៈ	ស្រុកត្រាំកក់ដែរ ខេត្តតាកែវដែរ ។

វណ្ណៈ	ចឹងនៅហ្នឹងហើយឆ្នាំ៧២-៧៣អីពូទៅខាងណាទៀត?

សុខាៈ	ខ្ញុំចូលធ្វើការចូលធ្វើកងទ័ព ។

វណ្ណៈ	ឆ្នាំណាពូ?

សុខាៈ	ឆ្នាំ៧២ ។

វណ្ណៈ	ពូយល់ឃើញយ៉ាងម៉េចបានពូចូល?

សុខាៈ	ដំនាន់ហ្នឹងខ្ញុំយល់ឃើញថា សម្តេចសីហនុឲ្យបងប្អូននាំគ្នាចូលព្រៃម៉ាគីតស៊ូ ។

វណ្ណៈ	ចឹងពូបានឮសម្តេចអំពាវនាវដែរ?

សុខាៈ	បាទ ។

វណ្ណៈ	សម្តេចសីហនុហ្នឹង?

សុខាៈ	បាទ ។

វណ្ណៈ	កាលពូចូលព្រៃម៉ាគីហ្នឹងចូលតស៊ូនៅម្តុំណា?

សុខាៈ	ចូលនៅក្នុងឃុំតាភេមហ្នឹងតែម្តង ។

វណ្ណៈ	ចឹងចូលនៅឃុំតាភេមមុនដំបូងកាន់កាំភ្លើងបណ្តោយ?

សុខាៈ	បាទ ។

វណ្ណៈ	ចូលទៅហ្នឹងពូនៅកងពលកងវរៈប៉ុន្មាន?

សុខាៈ	កាលហ្នឹងមិនទាន់មានកងពលទេ ចូលនៅឈូបឃុំសិនដល់ពាក់កណ្តាលឆ្នាំ៧២នៅកងស្រុក ។

វណ្ណៈ	ចឹង៧២នៅកងស្រុក?

សុខាៈ	បាទ ។

វណ្ណៈ	ចឹងចេញពីកងស្រុក?

សុខាៈ	ចេញពីកងស្រុកមកកងតំបន់ ។

វណ្ណៈ	នៅកងតំបន់ហ្នឹងពីណាគេជាអ្នកគ្រប់គ្រង?

សុខាៈ	កាលហ្នឹងតំបន់១៣គណៈតំបន់កាលហ្នឹងមិនជាពីណាខ្ញុំអត់ស្គាល់ ជំនាន់ហ្នឹងអត់ស្គាល់ទេ ។

វណ្ណៈ	ចឹងមិនទាន់ស្គាល់ទេ?

សុខាៈ	បើនៅកងអគ្គភាពតំបន់ហ្នឹងបង បូគាត់កាន់វរៈសេនាធំ ។

វណ្ណៈ	តំបន់ហ្នឹងតា បូ?

សុខាៈ	បងបូហ្នឹងគាត់កាន់ក្នុងកងវរយមាន១០០នាក់ហ្នឹង គាត់កាន់វរៈសេនាធំហ្នឹង ។

វណ្ណៈ	គាត់មានឈ្មោះអីបូ?

សុខាៈ	គាត់មិនដឹងឈ្មោះ អីបូ បង បូស្រែអំបិលហ្នឹង ។

វណ្ណៈ	ចឹងគាត់កាន់កងវរយមិនមែនជាប្រធានកងពលទេ?

សុខាៈ	អត់ទេ ។

វណ្ណៈ	ចឹងពូកាន់ហ្នឹងរយៈពេលតស៊ូឆ្នាំ៧២-៧៣-៧៤និង៧៥ហ្នឹង តើពូមានបាញ់ជាមួយកងទ័ពលន់ នល់ទេ?

សុខាៈ	ជំនាន់ហ្នឹងវៃគ្នាជាមួយទាហានលន់ នល់ ។

វណ្ណៈ	ចឹងវៃជាមួយទាហាន លន់ នល់?

សុខាៈ	បាទ ។

វណ្ណៈ	ចឹងខាងកំលាំងខ្មែរក្រហមកាលហ្នឹងមានច្រើនទេឬមិនទាន់មានច្រើនទេ?

សុខាៈ	មានពេញដីទាំងអស់ ។

វណ្ណៈ	ចឹងមានច្រើន?

សុខាៈ	មានច្រើន ។

វណ្ណៈ	ហើយកាលហ្នឹងអាវុធអីបានមកពីណា?

សុខាៈ	មិនដឹងបានមកពីណាដែរ ខ្ញុំមិនបានដឹងដែលមិនជាបានមកពីណា ។

វណ្ណៈ	ចឹងដឹងតែប្រើ?

សុខាៈ	ដឹងតែប្រើ ។

វណ្ណៈ	ចឹងអត់មានបានពុថាមកចិនជំនួយអីទេ?

សុខាៈ	អត់ដឹងទេ ដឹងថាវៃទាហានបានដឹងបើដឹងថាមកពីណាពីណីមិនបានដឹងទេ គាំភ្លើងទំនើប១ដឹង មកពីណា ។

វណ្ណៈ	ចឹងកាលហ្នឹងឡើងវៃដំបូងពូមានការភ័យខ្លាចទេកាលហ្នឹង?

សុខាៈ	ធម្មតា ។

វណ្ណៈ	អត់មានភ័យទេ?

សុខាៈ	បាទ!នៅកងឈ្លបឃុំវាឆ្អែតឆ្អល់ហើយ ធ្លាប់ជួបការលំបាកដល់មកជួបលំបាកធម្មតា ។

វណ្ណៈ	បាទ!ចឹងពេលវៃជាមួយទាហានលន់ នល់ហ្នឹង មានឃើញខាងទាហានលន់ នល់មានរបួស មានស្លាប់ហើយខាងខ្មែរក្រហមមានត្រូវរបួសមានស្លាប់ដែរ?

សុខាៈ	មានដូចគ្នាជំនាន់ហ្នឹង សង្គ្រាមមានស្លាប់មានរបួសចឹងដូចគ្នាហ្នឹង ។

វណ្ណៈ	ចឹងខ្មែរក្រហមវៃរំកិលរហូតទាល់តែបានជ័យជំនះនៅឆ្នាំ៧៥ហ្នឹង?

សុខាៈ	បាទ ។

វណ្ណៈ	ចឹងខាងវៃឆ្នាំ៧៥ពូមកខាងណាវិញ វៃចូលដល់ភ្នំពេញដែលឬមួយអត់ទេកាលហ្នឹង?

សុខាៈ	ខ្ញុំនៅពីខាងលិចភ្នំពេញ នៅខាងកំបូល ។

វណ្ណៈ	ចឹងពូចូលបានត្រឹមកំបូលទេ?

សុខាៈ	បាទ ។

វណ្ណៈ	ចឹងកាលហ្នឹង១៧មេសា?

សុខាៈ	១៧មេសា ។

វណ្ណៈៈ	យ៉ាងម៉េចបានជាពូមិនបានចូលដល់ភ្នំពេញ?

សុខាៈ	នៅតាមអង្គភាពតាមកងវាមុខសញ្ញាយើងនៅត្រង់ណាវ៉ៃត្រង់ហ្នឹង ។

វណ្ណៈៈ	ចឹងវ៉ៃតាមមុខសញ្ញា?

សុខាៈ	បាទ ។

វណ្ណៈៈ	ចឹងពេលចូលដល់ភ្នំពេញហើយ ពូចូលបានត្រឹមកំបូល?

សុខាៈ	បាទ ។

វណ្ណៈៈ	ចឹងនៅត្រឹមកំបូលហើយគេមានបញ្ជូនពូទៅណាផ្សេងទៀតទេ?

សុខាៈ	អត់ទេ ដល់ហើយអង្គការគេបញ្ជូនមកខាងកំពង់សោម ។

វណ្ណៈៈ	ចឹង?

សុខាៈ	បាទ ។

វណ្ណៈៈ	៧៥ហ្នឹង?

សុខាៈ	បាទ ។

វណ្ណៈៈ	ចឹងមកដល់កំពង់សោមមានកងពលមានអីហើយ?

សុខាៈ	នៅកំពង់សោមមានកងពល១៦៤ហ្នឹង កាលវ៉ៃចូលភ្នំពេញហ្នឹងក៏មានកងពលដែល តែកាលហ្នឹងបងពលលេខ៣ ជំនាន់ហ្នឹង ។

វណ្ណៈៈ	បាទ ។

សុខាៈ	ដល់មកដល់កំពង់សោមផ្លាស់កងពលហើយមកជាកងពល១៦៤ ។

វណ្ណៈៈ	ចឹងកងពល១៦៤មានតា មាស មុតហ្នឹង?

សុខាៈ	តា មាស មុត តាមុត តា សេង តា សេង"ស្លាប់" ។

វណ្ណៈៈ	ចឹងតាសេងស្លាប់ហើយ?

សុខាៈ	តាសេងស្លាប់នៅជំរំ ។

វណ្ណៈៈ	ស្លាប់កាលណា?

សុខាៈ	ស្លាប់នៅជំរំថ្ងៃទី៥-៦ហ្នឹង ។

វណ្ណៈៈ	គាត់ស្លាប់ដោយសារអី?

សុខាៈ	ស្លាប់ដោយឈឺ ។

វណ្ណៈៈ	ចឹងគាត់ស្លាប់ឆ្នាំ៩០ជាង?

សុខាៈ ៩០ប៉ុន្មានទេកាលហ្នឹង«ជិតខាងនិយាយថា ថ្ងៃ៥-៦ឆ្នាំ៩៨»។

វណ្ណៈ ចឹងកាលនៅភ្នំពេញកងពលលេខ៣ពីណាជាអ្នកគ្រប់គ្រង?

សុខាៈ កាលហ្នឹងកងពលខេល៣ បងម៉េតនិងតា មុតកាលហ្នឹងគាត់កាន់កងពលលេខ៣។

វណ្ណៈ ចឹងមានតា មុតដែរ?

សុខាៈ បាទ។

វណ្ណៈ ចឹងបំបែកមកកងពល១៦៤មានតា មុតដែរ?

សុខាៈ បាទ។

វណ្ណៈ យ៉ាងម៉េចបានជាគេរំលាយកងពលលេខ៣មកវិញ?

សុខាៈ គេគ្រាន់តែផ្លាស់ឈ្មោះ។

វណ្ណៈ ចឹងគ្រាន់តែផ្លាស់ឈ្មោះមនុស្សដដែរ?

សុខាៈ បាទ។

វណ្ណៈ ចឹងមួយកងពលហ្នឹងមានប៉ុន្មានវរៈសេនាធំពូ?

សុខាៈ មានវរៈសេនាធំ៦៣ វរៈសេនាធំប៉ុន្មានភ្លេចឈ្មោះហើយយូរ។

វណ្ណៈ តែមានប៉ុន្មានវរៈ?

សុខាៈ មានបួនវរៈសេនាធំ។

វណ្ណៈ ចឹងបួនវរៈសេនាធំមានប៉ុន្មានវរៈសេនាតូច បីវរៈសេនាតូចបានមួយវរៈសេនាធំមែនទេ?

សុខាៈ ហ្នឹងហើយបីវរៈសេនាតូចស្មើមួយវរៈសេនាធំ។

វណ្ណៈ ចឹងបួនវរៈសេនាធំស្មើនិង១២វរៈសេនាតូច?

សុខាៈ បាទ។

វណ្ណៈ ចឹងមនុស្សប្រហែលជាច្រើនដែរ?

សុខាៈ មានច្រើនមួយកងៗពេញជិនាន់ហ្នឹង។

វណ្ណៈ ក្នុងមួយវរៈសេនាតូចមានប៉ុន្មាននាក់ទៅ?

សុខាៈ មើលមួយអនុសេនាធំមានបីកងហាកាលជិនាន់ហ្នឹង វរៈពេញៗជំនាន់ហ្នឹងយើងមិនដឹង។

វណ្ណៈ ចឹងបីកងហាមាន១០០នាក់ជាង មួយកងហាមាន៩០នាក់។

សុខាៈ មួយកងហាមាន៩០នាក់ជាង។

វណ្ណៈ ចឹងពូនៅកងពល១៦៤រហូតដល់វៀតណាមចូល?

សុខាៈ ដល់វៀតណាមចូល មើលឆ្នាំមុនវៀតណាមចូលគេដកខ្ញុំមកខាងកងចល័ត។

វណ្ណៈ មុនប្រហែលជាប៉ុន្មានខែ?

សុខាៈ មុនពីរឆ្នាំ ។

វណ្ណៈ ចឹងមានតែឆ្នាំ៧៧គេដកពូហើយចឹង?

សុខាៈ ពាក់កណ្តាល៧៧ ថា៧៧ចុះ ។

វណ្ណៈ ចឹង៧៧-៧៨និង៧៩នៅកងចល័តវិញ?

សុខាៈ បាទ ។

វណ្ណៈ កងចល័តហ្នឹងក្នុងកងពលហ្នឹងដដែល?

សុខាៈ បាទ ។

វណ្ណៈ យ៉ាងម៉េចបានជាគេដកមកកងចល័តមកពីគេលែងទុកចិត្តយើង?

សុខាៈ កាលជំនាន់ហ្នឹងមានពាក់ព័ន្ធ តែយើងមានពាក់ព័ន្ធមានជាប់អីបន្តិចគេដកចេញហើយជំនាន់ហ្នឹង ។

វណ្ណៈ ចឹងពី៧៥ដល់៧៧ពូនៅកងពល១៦៤ខាងជើងទឹកហ្នឹង?

សុខាៈ អត់ទេខាងគោកខាងជើងទឹកផ្សេង ។

វណ្ណៈ ពួកជើងទឹកផ្សេងទៀត?

សុខាៈ ពួកនាវាផ្សេង ពួកគោកផ្សេង ។

វណ្ណៈ ចឹងពូនៅកងពល១៦៤ដែលតែមិនមែនជើងទឹកទេ?

សុខាៈ បាទ ។

វណ្ណៈ ចឹងពូនៅជើងគោក?

សុខាៈ បាទ ។

វណ្ណៈ ចឹងកងពល១៦៤មានជើងគោកដែរ?

សុខាៈ បាទ!មានជើងគោកជើងទឹក ។

វណ្ណៈ ចឹងគ្នាពូមានប៉ុន្មាននាក់នៅជើងគោកហ្នឹង?

សុខាៈ មានមួយកងពលទាំងអស់ហ្នឹងមានកងវរៈគោកផ្សេងទឹកផ្សេង ។

វណ្ណៈ ចឹងបែកចែកគ្នាទៅ?

សុខាៈ បាទ ។

វណ្ណៈ ចឹងនៅកន្លែងពូវិញជើងគោកពូមានគ្នាប៉ុន្មាន១០០នាក់ទៅ?

សុខាៈ អត់ដឹងទេ កាលហ្នឹងនិយាយទៅអត់មានអ្នកក្តាប់ ។

វណ្ណៈ   ចឹងខាងជើងគោកនិងការពារអីទៅ?

សុខាៈ   ការពារដែនគោកហ្នឹង ។

វណ្ណៈ   ដែនគោកការពារពីកន្លែងណាទៅកន្លែងណា?

សុខាៈ   កាលហ្នឹងខ្ញុំនៅកាំភ្លើងធំនៅ១០៥ ។

វណ្ណៈ   នៅកាំភ្លើង១០៥ហ្នឹងជាឈ្មោះអីគេ?

សុខាៈ   អាហ្នឹង១០៥មីលីម៉ែត្រហ្នឹង ។

វណ្ណៈ   នៅខាង១០៥ហ្នឹងពី៧៥ដល់៧៧ពូមានបានបាញ់ទៅខាងណាដែរ?

សុខាៈ   អត់មានបានបាញ់ទេ ជំនាន់ហ្នឹងអត់មានសង្គ្រាមផងជំនាន់ហ្នឹង ។

វណ្ណៈ   ចឹងអត់ទាន់មានសង្គ្រាមទេ?

សុខាៈ   នៅការពារហ្នឹងតំបន់កំពង់សោមហ្នឹង ។

វណ្ណៈ   ការពារពីណាទៅណា?

សុខាៈ   ការពារកំពង់សោមហ្នឹងតែម្តង ។

វណ្ណៈ   ចឹងការពារកំពង់សោមប្រធានតា មាស មុត?

សុខាៈ   បាទ ។

វណ្ណៈ   គាត់មានដែលទៅប្រជុំប្រាប់យើងថាយ៉ាងម៉េចៗទេ?

សុខាៈ   អត់ទេ ជំនាន់ហ្នឹងយើងអត់មានប្រជុំទេ យើងយុវជនយើងអត់មានតួនាទីអី ។

វណ្ណៈ   ហូបចុកយ៉ាងម៉េចដែលពូ?

សុខាៈ   ការហូបចុកធម្មតា ។

វណ្ណៈ   ចឹងអត់មានលំបាកទេ?

សុខាៈ   អត់មានលំបាកទេ នៅទ័ពអត់មានលំបាកទេ មកនៅកងចល័តបានជួបការលំបាកខ្លះ ។

វណ្ណៈ   ចឹងនៅកងពល១៦៤ហ្នឹងមានទ័ពនារីទេ?

សុខាៈ   ចឹមាន ។

វណ្ណៈ   ចឹងមាននារីដែរ?

សុខាៈ   បាទ ។

វណ្ណៈ   ចឹងកាលហ្នឹងទ័ពខាងនារីនិងទ័ពខាងបុរសហ្នឹងអាចស្រឡាញ់គ្នារៀបការបានទេ?

សុខាៈ ជំនាន់ហ្នឹងខ្ញុំមិនសូវដឹងទេ ឃើញគេរៀបការអង្គការគេរៀបឲ្យ ខ្ញុំមិនដែលស្រឡាញ់គ្នាមិនដែលមានទំនាក់ទំនងគ្នាអីជង គេនៅអង្គភាពគេ យើងនៅអង្គភាពយើងអត់មានរឿងឆ្លេចឆ្លាចទំនាក់ទំនងអីទេជំនាន់ហ្នឹង ។

វណ្ណៈ ចឹងយើងអត់មានទៅនិយាយលេងជាមួយស្រីៗអត់បានទេ គេតឹងតែង?

សុខាៈ មិនដែលទំនាក់ទំនងមានពេលណានិយាយពេលហ្នឹងគិតរឿងធ្វើការ កាលហ្នឹងព្រលឹមឡើងធ្វើការងារអត់មានដែលបាននិយាយអី ការងារយើងផ្សេងមុខសញ្ញាយើងផ្សេង ដូចថាទៅទំនាក់ទំនងនិយាយលេងតឹង ។

វណ្ណៈ ចឹងពូការពារហ្នឹងកុំឲ្យសត្រូវខាងណាមក ខាងវៀតណាមចូលឬការពារមិនឲ្យប្រជាជនរត់?

សុខាៈ កាលហ្នឹងមិនដឹងជាខាងណាអង្គការគេចាត់តាំងនៅការពារកំពង់សោម ខ្ញុំដឹងថានៅការពារ ។

វណ្ណៈ ចឹងមានដែលឃើញជនជាតិវៀតណាមរត់ឆ្លងកាត់ទៅថៃទៅអីទេ?

សុខាៈ អត់ទេ ។

វណ្ណៈ ចឹងអត់មានទេយើងនៅខាងជើងគោក?

សុខាៈ បាទ ។

វណ្ណៈ ចឹងមានឃើញខ្មែរយើងមានរត់ទៅខាងជាយដែនអីទេ?

សុខាៈ ជំនាន់ហ្នឹងអត់ទេ ចុះជំនាន់ហ្នឹងមានរត់ទៅណា អត់មានរត់ទៅណាអត់ ដល់៧៩វៀតណាមចូលបានមានរត់ទៅថៃ ។

វណ្ណៈ ចឹងនៅក្នុងអង្គភាពពូក្រោយមកមានបាត់ខ្លួនមានចាប់ខ្លួនខ្លះទេមានទេ?

សុខាៈ មានហើយកងអ្នកមានកំហុសកងចល័តអីបាត់ខ្លួនគេយកទៅកសាងទឹកសាបទឹកអីទៅ កាលហ្នឹងដឹងថាអង្គការយកទៅកសាងមិនដឹងជាយកទៅណា ។

វណ្ណៈ ចឹងមានបាត់ខ្លួនដែរ?

សុខាៈ បាទ ។

វណ្ណៈ ចឹងពូនៅខាងកំពង់សោមឮថាមានគុកដែលចឹងបើគេចាប់មកដាក់គុកទៅខាងណាវិញ?

សុខាៈ ហ្នឹងនៅទឹកសាបនៅក្បាលស្ពានទឹកសាប ឃើញគេបញ្ជូនមកខាងហ្នឹងគេយកមកទឹកសាបហ្នឹងហើយ ។

វណ្ណៈ ចឹងគេយកមកខាងទឹកសាប?

សុខាៈ បាទ ។

វណ្ណៈ ចឹងពូមានដែលដឹងថាគេយកមកខាងវត្តអង្គតាញ្ញាណទេ?

សុខាៈ វត្តអន្តគាញ្ញាណមានពុស្សូរ្យគេយកមកដាក់នៅហ្នឹងដែរ នៅកំពង់សោមវត្តអន្តគាញ្ញាណមាន នៅហ្នឹង បើទឹកសាបនិងមាន ។

វណ្ណៈៈ ចឹងពួពុគេមានគុកនៅហ្នឹង?

សុខាៈ ចុះពួកខ្ញុំធ្វើការកងចល័តនៅហ្នឹង កន្លែងគេអប់រំនៅព្រែកម្នាងហ្នឹងមើលឃើញ ។

វណ្ណៈៈ ចឹងមើលឃើញ?

សុខាៈ បាទ!ព្រែកម្នាងម្នាក់ ។

វណ្ណៈៈ ចឹងផ្នែកទោសនៅហ្នឹង ក្រោយមកគេយកទៅសម្លាប់អីមានទេ?

សុខាៈ យើងមិនដឹងជាគេយកទៅណា យើងមិនបានដឹងដែរ ។

វណ្ណៈៈ ចឹងពូមានពាក់ព័ន្ធមិនទុកចិត្តយ៉ាងម៉េច ហើយដកមកខាងកងចល័តគ្រួសារពូមានមូលហេតុអី កាលហ្នឹង?

សុខាៈ មូលហេតុកាលហ្នឹងដោយសារខ្ញុំមានពាក់ព័ន្ធគេយកប៉ាខ្ញុំជាប់និន្នាការគេយកប៉ាទៅសម្លាប់ ជាប់និន្នាការខ្មាំង ខ្ញុំមិនបានដឹងថាគេយកឪពុកខ្ញុំយកទៅសម្លាប់ចោលខ្ញុំអត់ដឹងផងហ្នឹង ។

វណ្ណៈៈ ចឹងដោយសារថាអង្គការយកឪពុកទៅសម្លាប់?

សុខាៈ បាទ!យកទៅសម្លាប់តាំងពី៧៣នោះអត់ដឹង ដល់៧៥គេដកខ្ញុំចេញអះ ដល់៧៧បានដឹង ។

វណ្ណៈៈ ចឹងមានសម្លាប់តាំងពី៧៣មក មិនមែនចាប់ចូលឆ្នាំ៧៥បានមានការសម្លាប់ទេ?

សុខាៈ បាទ ។

វណ្ណៈៈ ចឹងកាលនៅកងចល័តហ្នឹងពូមានដែលបញ្ជូនពូមានខាងវាលវិញអះខាងស៊ីងហាវ?

សុខាៈ ស៊ីងហាវខ្ញុំនៅហ្នឹង គេដកពីកងកេងមកនៅស៊ីងហាវ នៅកសាងនៅស៊ីងហាវធ្វើដៃធ្វើអី ធ្វើ ទំនប់ធ្វើអី ។

វណ្ណៈៈ ចឹងស៊ីងហាវហ្នឹងគេមានរ៉ែថ្មយកទៅធ្វើ?

សុខាៈ បាទ!អង្គការឲ្យរ៉ែថ្ម ។

វណ្ណៈៈ ចឹងនៅកន្លែងរ៉ែថ្មហ្នឹងមានចាប់មនុស្សយកទៅណាទៀតទេ?

សុខាៈ អត់ទេ ជំនាន់ហ្នឹងអត់មានគេចាប់ទេ អង្គភាពហ្នឹងនៅហ្នឹងទាំងអស់អត់មានទៅណាទៅណីអីទេ កាលហ្នឹង ។

វណ្ណៈៈ ចឹងកាលហ្នឹងរ៉ែថ្មយកទៅធ្វើអីគេ?

សុខាៈ យកទៅធ្វើដៃយកទៅធ្វើអីហ្នឹង យកទៅធ្វើដៃធ្វើទំនប់អីហ្នឹង នៅជីកអន្លូងជីកអីហ្នឹង ។

វណ្ណៈៈ ធ្វើដែសម្រាប់ឲ្យកប៉ាល់ចូលចតឬមួយយ៉ាងម៉េចពូ?

សុខា: មិនដឹងជាដែស្អីគេទេ ជនាន់ហ្នឹងយើងដឹងតែធ្វើមិនដឹងគេធ្វើអីផង ។

វណ្ណៈ: កាលហ្នឹងដែនៅស្ទឹងហាវហ្នឹង ដូចថាជិតហើយឬនៅឬធ្វើមិនទាន់ហើយទេ?

សុខា: នៅទេ ធ្វើមិនទាន់ហើយផងវៀតណាមចូលប្រឹបមកធ្វើមិនទាន់ហើយផង ។

វណ្ណៈ: ចឹងកាលហ្នឹងមិនទាន់ធ្វើហើយទេ?

សុខា: នៅទេជនាន់ហ្នឹង ។

វណ្ណៈ: ចឹងនៅកន្លែងស្ទឹងហាវហ្នឹងពីណាគេជាអ្នកគ្រប់គ្រងពូ?

សុខា: អ្នកគ្រប់គ្រងនៅហ្នឹងអត់ដឹង ។

វណ្ណៈ: អ្នកគ្រប់គ្រងឲ្យយើងវៃថ្មអីហ្នឹង?

សុខា: តាមកងអង្គភាពមួយៗហ្នឹង បើអ្នកគ្រប់គ្រងធំមិនដឹងទេ ។

វណ្ណៈ: ចឹងអ្នកគ្រប់គ្រងតាមអង្គភាពតាមវរៈហ្នឹងពីណាគេមានស្គាល់ទេ?

សុខា: មានបងផន បងឈន ។

វណ្ណៈ: ចឹងអ្នកគ្រប់គ្រងផ្ទាល់?

សុខា: បាទ! បងផនកងវរៈ បងឈនហ្នឹងជាប្រធានវរៈសេនាធំ ។

វណ្ណៈ: បងឈន?

សុខា: បាទ ។

វណ្ណៈ: ចឹងបងឈនជាប្រធានវរៈសេនាធំ?

សុខា: បងផនជាប្រធានវរៈសេនាតូច ប្រធានកងចល័តហ្នឹង ។

វណ្ណៈ: ចឹងបងឈន?

សុខា: បងឈនជាប្រធានវរៈសេនាធំ ។

វណ្ណៈ: ចឹងគាត់កាចទេ?

សុខា: គាត់អត់មានកាចទេ គាត់ធម្មតាជនាន់ហ្នឹងអត់មានវៃដុំអត់ទេ គេអត់មានវៃដុំអត់ទេ កាលជនាន់ហ្នឹងអត់មានវៃដុំទេ កាលខ្ញុំនៅអង្គភាព បើថាយើងមានកំហុសអីគេប្រដុកសាង ។

វណ្ណៈ: ចឹងអ្នកដែលមកវៃថ្មធ្វើស្ទឹងហាវមានគ្នាច្រើនទេ?

សុខា: មានច្រើន មានពីរកងវរៈឬបីកងវរៈទេ កាលហ្នឹងខ្ញុំភ្លេច ។

វណ្ណៈ: ប្រហែលជាប៉ុន្មានរយនាក់ពូមានដឹងទេ?

សុខា: យី!ស្មានជនាន់ហ្នឹងបើមិនពីរកងវរៈបីកងវរៈភ្លេចហើយជនាន់ហ្នឹងកង២០ កង២១ យ៉ាងម៉េចមិនដឹងទេ នៅពីរកងវរៈនៅកងចល័តស្ទឹងហាវហ្នឹង ។

វណ្ណៈ	ចឹងពូធ្វើនៅហ្នឹងរហូតដល់វៀតណាមចូល?

សុខៈ	ធ្វើហ្នឹងរហូតដល់វៀតណាមចូល ។

វណ្ណៈ	ចឹងនៅពេលដែលបានមកធ្វើកម្មករនៅស៊ឹងហាវហ្នឹងរបបហូបចុកមានគ្រប់គ្រាន់ដែរ?

សុខៈ	មានពេលខ្វះខាតមួយខែពីរចឹង អង្គការថាខ្វះស្បៀងអីហ្នឹងហូបបបរ ។

វណ្ណៈ	ចឹងកាលហ្នឹងមានខ្វះខាតបន្តិចបន្តួច?

សុខៈ	បាទ ។

វណ្ណៈ	ចឹងកាលជំនាន់ហ្នឹងពូអត់មានសុំគេមកលេងស្រុកកំណើតអីទេ?

សុខៈ	ជំនាន់ហ្នឹងអត់មានសុំគេមកលេងផ្ទះទេ អត់មាននឹកនាផ្ទះសំបែងផងគិតរឿងធ្វើការមិនដែលទៅសុំគេ អត់មានទៅសុំគេដែរ កាលជំនាន់ហ្នឹងគេថាអង្គការចាត់តាំង ។

វណ្ណៈ	ចឹងពូនៅធ្វើនៅហ្នឹង ធ្វើនៅស៊ឹងហាវហ្នឹងរហូតដល់៧៩?

សុខៈ	ជម្លៀសចេញពីហ្នឹងរត់ចេញពីហ្នឹងមកទៀត ។

វណ្ណៈ	យ៉ាងម៉េចបានជាពូមិនរត់ទៅផ្ទះ?

សុខៈ	ទៅតាមអង្គភាពខ្ញុំមកតាមអង្គភាពពេលវៀតណាមចូល យើងមកតាមអង្គភាព ។

វណ្ណៈ	ចឹងកាលហ្នឹងពូខ្លាចវៀតណាមឬមួយក៏យ៉ាងម៉េច?

សុខៈ	ចុះជំនាន់ហ្នឹងមានដឹងអី គេថាវៀតណាមចាប់បានដោតខ្សែចងចឹង ចឹងមកតាមអង្គភាពមកចឹងទៅ ។

វណ្ណៈ	មកតាមអង្គភាពការហ្នឹងពូមកតាមផ្លូវណា?

សុខៈ	ខ្ញុំចេញពីស៊ឹងហាវមកពាយដូង ពាយដំរាំងមក មកអន្ទង់ស អង្កើបផុសឡើងមកដីយើងចាក់មកខាងស្រែអំបិល ឆ្លងស្រែអំបិលមកបានមកពោធិ៍ចឹង ចេញពីពោធិ៍ចឹងមកកោះខ្យាង ចេញពីកោះខ្យាងបានធ្លាក់ថ្មបាំង ចេញពីផ្ទះបាំងបានមកឬស្សីជ្រុំយើងនេះអូរសោមហ្នឹង ។

វណ្ណៈ	បាទ ។

សុខៈ	បានឬស្សីជ្រុំហ្នឹងបានឃួនស្នាក់ពីមុននេះទៀតបានខ្ញុំដកផុងចឹងមកបានរត់ចឹងបានវាងភ្នំខ្មោចចឹងទៅចំការបុសយើងថ្មដាហ្នឹង ឆ្លងទឹកឃួនចាប់ជាប់ចឹងទៀតទៅថៃជំនាន់ហ្នឹង ។

វណ្ណៈ	ចឹងឃួនចាប់ជាប់?

សុខៈ	ឃួនស្នាក់ជាប់ហ្នឹង មានដឹងថាថៃណា និយាយថៃដល់អ្នកចេះថៃសួរថាទៅណា ថាទៅចឹងកកចឹងនិយាយថៃទៅ ដល់មកសង្កាត់ក្រោយវាសួរទៀត ដល់ថាឱ១បានដឹងថាឃួនដឹងថាវៀតណាម ។

វណ្ណៈ ចឹងវៀតណាមអត់ចាប់មកទេ?

សុខាៈ អត់ ដល់នេះទ័ពវៀតណាមប្រមូលយើងទុកមួយដុំអត់ឲ្យយើងឆ្លងទឹកទៅឆ្លងព្រែកស៊ីងហ្នឹង ថ្មដាអត់មានឲ្យឆ្លងទៅនោះទេ ឲ្យទៅខាងកោះកុងវិញឲ្យទៅស្រុកកំណើត ហ្នឹងខ្ញុំដាច់ស្បៀង ហើយជួបវៀតណាមហ្នឹង ដល់ជួបវៀតណាមគេអ្នកមានអង្ករគេរត់ទៅខ្ញុំដាច់ស្បៀងបាន វៀតណាមឲ្យស្បៀង ។

វណ្ណៈ ចឹងនៅពេលវៀតណាមឲ្យអាហារហើយយ៉ាងម៉េចបានជាពូមិនត្រឡប់ក្រោយពូទៅមុខទៀត កាលហ្នឹង?

សុខាៈ ខ្ញុំអត់មានទៅមុខទេ ខ្ញុំត្រឡប់ក្រោយវិញតើ វៀតណាមបញ្ជូនមកខាងកោះកុង ។

វណ្ណៈ ចឹងយ៉ាងម៉េចទៀតទៅ?

សុខាៈ បញ្ជូនមកនៅកោះកុងបានពីរខែបានបញ្ជូនទៅនៅកំពង់សោមនៅកំពង់សោមហើយបានបញ្ជូន ទៅស្រុកកំណើត ។

វណ្ណៈ ចឹងនៅពីរខែបានបញ្ជូនទៅកំពង់សោម?

សុខាៈ បាទ! នៅកំពង់សោមមួយខែទៀតបានបញ្ជូនទៅស្រុកកំណើតវិញ ។

វណ្ណៈ ចឹងនៅពេលដល់ស្រុកកំណើតពូនៅស្រុកកំណើតរហូតទៅចឹង?

សុខាៈ បាទ!ខ្ញុំនៅបានតែមួយឆ្នាំពីរឆ្នាំខ្ញុំចេញពីស្រុកមកទៀតមក មកនៅបាត់ដំបងនៅអីហើយទៅ នៅស្រុកវិញហើយមកនៅកោះកុងបានមកនៅនេះ ។

វណ្ណៈ ចឹងឆ្នាំ៨០ពូចេញពីស្រុកវិញ?

សុខាៈ ឆ្នាំ៨១ចេញ ។

វណ្ណៈ ចឹងកាលហ្នឹងចេញពីខេត្តតាកែវហ្នឹងចេញមកនៅណាមកនៅបាត់ដំបង?

សុខាៈ មកនៅបាត់ដំបង ។

វណ្ណៈ នៅបាត់ដំបងហ្នឹងនៅខេត្តប្ត្រ នៅណា?

សុខាៈ មកនៅស្រុកបាណន់ ។

វណ្ណៈ ពូមកនៅហ្នឹងធ្វើអី?

សុខាៈ មកនៅធ្វើស្រែធ្វើចំការមានបងប្អូននៅហ្នឹង ។

វណ្ណៈ នៅហ្នឹងរហូតដល់ឆ្នាំណា?

សុខាៈ នៅហ្នឹងបានបីឆ្នាំបានគ្រួសារខ្ញុំស្លាប់ទៅបានខ្ញុំវិលទៅស្រុកវិញ ។

វណ្ណៈ ចឹងប្រពន្ធពូស្លាប់?

សុខាៈ បាទ! គ្រួសារមុនស្លាប់ ។

វណ្ណៈ ចឹងពូទៅស្រុកវិញបានប៉ុន្មានឆ្នាំបានពូមក?

សុខាៈ ខ្ញុំទៅស្រុកវិញបានប៉ុន្មានខ្ញុំមកនៅកោះកុង ហើយមកនៅកោះកុងបានបួនឆ្នាំបានខ្ញុំវិលមកនេះវិញ ។

វណ្ណៈ ចឹង?

សុខាៈ បាទ! បានឡើងពីកោះកុងមកនៅនេះមក ដើរកាត់ភ្នំ ។

វណ្ណៈ ចឹងកាលទៅស្រុកវិញបានរយៈពេលប៉ុន្មានទេ?

សុខាៈ នៅបានប៉ុន្មានយ៉ាងច្រើនបានមួយឆ្នាំ ភ្លេចហើយជំនាន់ហ្នឹង ។

វណ្ណៈ ចឹងកាលដែលមកនៅកោះកុងពូនៅធ្វើអី?

សុខាៈ នៅរកស៊ីគេឯងហ្នឹង ។

វណ្ណៈ ចឹងនៅរកស៊ីនៅកោះកុងហ្នឹង?

សុខាៈ បាទ ។

វណ្ណៈ ចឹងអត់មានបានចូលទៅបំរើខ្មែរក្រហមអីទេ?

សុខាៈ អត់ទេ នៅកោះកុងដល់ឆ្នាំ៩៨ខ្ញុំមកនេះវិញ ។

វណ្ណៈ មកនៅណា?

សុខាៈ មកនៅហ្នឹង ។

វណ្ណៈ ចឹងមកនៅហ្នឹងចូលតំបន់ខ្មែរក្រហមហើយចឹង?

សុខាៈ នៅតំបន់ខ្មែរក្រហមហ្នឹង ៩៣-៩៨ជំនាន់ហ្នឹង ខ្ញុំ៩៣មកនៅហ្នឹង ។

វណ្ណៈ ចឹងចេញពីកោះកុង?

សុខាៈ បាទ ។

វណ្ណៈ ចឹងមកនៅតំបន់ខ្មែរក្រហមមកនៅកន្លែងណាមកនៅវាលវែង?

សុខាៈ មកនៅវាលវែងមកនៅខាងត្បូងស្ទឹងខាងកើតស្ទឹង ។

វណ្ណៈ ចឹងពូនឹកឃើញយ៉ាងម៉េច ពូនៅរកស៊ីខេត្តកោះកុងសោះហេតុអីបានពូមកចូលបំរើខាងខ្មែរក្រហមវិញ ។

សុខាៈ ខ្ញុំនឹកឃើញថាមកនៅហ្នឹងមានដីធ្លីចឹង មកនៅវិញមានដីមានធ្លី ។

វណ្ណៈ ចឹងពេលមកយ៉ាងម៉េចបានជាខ្មែរក្រហមបើកច្រកឲ្យយើងចូលយើងស្គាល់គ្នាឬមួយយ៉ាងម៉េច?

សុខាៈ មានស្គាល់គ្នាកាលនៅអន្តភាពចាស់ជាមួយគ្នា គេបួលមកៗមក ។

វណ្ណៈ ចឹងគេឡើងទៅជួបនៅកោះកុងចឹង?

សុខាៈ បាទ ។

វណ្ណៈ នៅពេលពូចូលមកនៅឆ្នាំ៩៨ហ្នឹង សឹងថាគេលែងមានវ៉ៃគ្នាហើយហ្នឹងលែងវ៉ៃជាមួយវៀតណាមលែងវ៉ៃជាមួយអីហើយនៅវ៉ៃជាមួយខ្មែរគ្នាឯងហ្នឹងទេ?

សុខាៈ ៩៨មកនៅហ្នឹងវិញ ដល់ថ្ងៃ៥ទៅ៦បានរត់ទៅជំរំទៀត ដល់គេវ៉ៃគ្នាសារក្រោយបានទៅជំរំ ។

វណ្ណៈ ចឹងកាលពូនៅឆ្នាំ៩៣-៩៨ហ្នឹងប្រធានកងពលពីណាគេ កាលនៅវាលវែងនេះ?

សុខាៈ កាលហ្នឹងគឹមពៅ ។

វណ្ណៈ គាត់ឈ្មោះ គឹម ពៅឬឈ្មោះអីពៅ?

សុខាៈ មិនដឹងជាឈ្មោះអីពៅទេ ខ្ញុំហៅបងពៅ ។

វណ្ណៈ សព្វថ្ងៃគាត់នៅហ្នឹងដែរ?

សុខាៈ គាត់នៅក្បាលគ្រោះ ។

វណ្ណៈ គាត់ជាប្រធានកងពល?

សុខាៈ បាទ ។

វណ្ណៈ ចឹងប្រធានធំជាងពូពៅទៀតពីណា?

សុខាៈ អត់ដឹង ។

វណ្ណៈ ចឹងនៅហ្នឹងដឹងថា ពូពៅទេ?

សុខាៈ ដឹងថា បងពៅនៅកងជាមួយគាត់ហ្នឹង ។

វណ្ណៈ ចឹងកាលពូចូលមកឆ្នាំ៩៣ហ្នឹងកាន់កាំភ្លើងអី កាលហ្នឹងអត់មានប្រាក់ទេ?

សុខាៈ អត់ទេ ។

វណ្ណៈ តែរបបហូបចុកមានគ្រប់គ្រាន់?

សុខាៈ របបហូបចុកមានអីមានទិញដូរណាយើងធ្វើស្រែចំការបាន ។

វណ្ណៈ កាលពូចូលមកដល់ដំបូងហ្នឹង ពូមានសង្កេតឃើញថាវាលវែងហ្នឹងសម្បូរព្រៃសម្បូរសត្វច្រើនទេ កាលហ្នឹង?

សុខាៈ សត្វយប់ឡើងយំជុំវិញផ្ទះហ្នឹង នៅសុទ្ធតែព្រៃជិនាន់ហ្នឹង ។

វណ្ណៈ	ចឹងចាប់ផ្ដើមខ្សោយអស់សត្វព្រៃឈើអីហ្នឹង ប្រហែលជាឆ្នាំណាពូមានបានសង្កេតឃើញទេកាលហ្នឹង?

សុខាៈ	ទើបអស់ប្រហែលជាបីបួនឆ្នាំមុននេះ មុនៗសត្វនៅព្រៃហ្នឹងមាន ទើបចាប់ខ្សោយប្រហែលជា១០ឆ្នាំចឹងចុះ លែងមានសត្វកាលពីមុនសត្វសម្បូរ មានក្រុមហ៊ុនទិញព្រៃ មានម៉ាស៊ីនកាត់ពេញព្រៃទៅវាបាត់អស់ហើយ ។

វណ្ណៈ	វារត់ឡើងភ្នំ?

សុខាៈ	វាមិនដឹងជារត់ទៅណាអស់ ពីមុនមានដំរី មានខ្ទីងក៏ជួបតែញឹកហ្នឹង ទៅក្រោយខាងនោះស៊ីងជួបខ្ទីងជួបទន្សោងតែឥឡូវដើរមួយថ្ងៃមិនជួបផង ។

វណ្ណៈ	ទន្សោងធំៗ?

សុខាៈ	បាទ ។

វណ្ណៈ	ធំប៉ុនគោ?

សុខាៈ	បាទៗ!ខ្ទីងប៉ុនក្របី ។

វណ្ណៈ	ចឹងខ្ទីងធំៗទៀត?

សុខាៈ	បាទ!ខ្ទីងចង់ប៉ុនដំរីចឹង ទៅព្រៃខាងនោះជួបហើយខ្ទីង ឥឡូវទន្សោងក៏គ្មានដើរដល់ណាក៏គ្មានឃើញមានវាស្ងាត់បាត់អស់ហើយ ។

វណ្ណៈ	ខ្លាចវារត់ចូលថៃអីអស់?

សុខាៈ	មិនដឹងជាទៅណា កាលជំនាន់មុនមានណាគ្រឹកគ្រែងមានម៉ាស៊ីអារណា មានក្រុមហ៊ុនណា ។

វណ្ណៈ	អាម៉ាស៊ីនអារហ្នឹងឮជាងគាំភ្លើងទៀត?

សុខាៈ	បាទ!បើចឹងអារលំព្រៃសត្វវាផ្អើលអស់ទៅ ពីមុនសត្វសម្បូរតើ ។

វណ្ណៈ	ចឹងនៅហ្នឹងចាប់បង្កើតភូមិឃុំស្រុកអីចាប់ពីពេលណាមកពូមានដឹងទេ?

សុខាៈ	ចាប់ពីភូមិឃុំស្រុកតាំងពីឆ្នាំមើលឆ្នាំឡើងពីជំរំឆ្នាំ៩៨ ឡើងមកពីជំរំមកនៅហ្នឹងចាប់កើតស្រុកភូមិរហូត ។

វណ្ណៈ	ចឹងចាប់ពីក្រោយសមាហរណ៍កម្មហើយបានមានបង្កើតជាភូមិអី?

សុខាៈ	បាទ!តែមិនទាន់មានសម្បូរប្រជាជនទើបឥឡូវមានប្រជាជនមកនៅ ពីមុនអត់មានទេ ។

វណ្ណៈ	ចឹងឥឡូវមានប្រជាជនច្រើនទេ?

សុខាៈ	បាទ ។

វណ្ណៈ	មានប្រជាជនថ្មី?

សុខៈ មានថ្មីចាស់នៅជាមួយគ្នា មកនៅហ្នឹងដំបូងបើចង់ទៅពោធិសាត់ទាល់តែដេកផ្លូវពីយប់នោះបានទៅដល់ ។

វណ្ណៈ បាទ ។

សុខៈ នៅដំបូងផ្លូវហ្នឹងទៅមិនទាន់កើត ពួកខ្ញុំអត់មានទាន់ទៅពោធិសាត់បានទេ មានតែទៅខាងសំឡូតទៅបាត់ដំបង ទើបតែធ្វើផ្លូវ៥៦នេះហើយបានៗទៅពោធិសាត់ ។

វណ្ណៈ ចឹងទៅទាល់តែដេកតាមផ្លូវ?

សុខៈ បាទ! ទៅទាល់តែដេកផ្លូវពីយប់ទៅបីយប់បានដល់ ។

វណ្ណៈ ចឹងជួបការលំបាកណាស់ធ្វើដំណើរដេកផ្លូវ ដេកក្នុងព្រៃក្នុងអី?

សុខៈ ចុះធ្លាប់ហើយជារឿងធម្មតា ធ្លាប់រឹករឹន ។

វណ្ណៈ ចឹងកាលដែលពូមកដល់ដំបូងមិនទាន់មានផ្ទះធំចឹងទេ?

សុខៈ នៅដំបូងនៅតាមស្ទឹងដល់ហើយបានមកនៅនេះ កាលមុនដំបូងនៅក្រោយស្ទឹង ។

វណ្ណៈ បាទ ។

សុខៈ ដល់គេចេញមកនៅនេះអស់វាស្ងាត់បាននាំគ្នាមកនៅនេះ អត់មានមនុស្សនៅទេភូមិចាស់ឥឡូវ ។

វណ្ណៈ ចឹងកន្លែងណាមានភូមិចាស់?

សុខៈ ភូមិចាស់នៅខាងក្រោយកើតស្ទឹងនោះ ស្ទឹងចាស់ទៅរហូតភូមិជនជាតិភូមិអីគេពីដើម ។

វណ្ណៈ ចឹងឥឡូវមានជនជាតិទេ?

សុខៈ ឥឡូវអត់មានជនជាតិទេមានតែភូមិចាស់គេ ភូមិចាស់គេមានស្វាយខ្នុរក្រូចភូមិជនជាតិពណ៌ហ្នឹង ។

វណ្ណៈ ជនជាតិទំព័រ?

សុខៈ បាទ ។

វណ្ណៈ ចឹងឥឡូវអត់មាននៅសល់ជនជាតិអីទេ?

សុខៈ ឥឡូវនៅមានសល់ពីរទៅបីគ្រួសារដែរ ។

វណ្ណៈ នៅខាងណាវិញ?

សុខៈ នៅខាងជើងនិងខាងត្បូងពីរបីគ្រួសារដែរ ។

វណ្ណៈ ចឹងដល់នៅតិចចឹងដូចជាខ្មែរយើងដែរ?

សុខាៈ ដូចយើងចឹងប្រកបមុខរបរដូចយើងដែរ មុនសមាហរណ៍កម្មហើយខ្ញុំទៅលេងស្រុកទៅរកម្តាយអីទៅតាមបាត់ដំបងទៅហ្នឹងដេកផ្លូវបីយប់អីចឹង ទៅពីនេះទៅដេកនៅអំពិលពីរចេញពីអំពិលពីរទៅដេកសំឡូតបានទៅដល់បាត់ដំបងបានទៅស្រុកមកវិញ ។

វណ្ណៈ បាទ ។

សុខាៈ កាលហ្នឹងផ្លូវហ្នឹងទៅមិនទាន់រួចទេ ។

វណ្ណៈ ចឹងកាលហ្នឹងយើងចេញចូលទៅរកម្តាយហ្នឹងនៅតឹងតែងនៅឡើយទេ?

សុខាៈ អត់មានតឹងតែងទេ សមាហរណ៍កម្មហើយ ។

វណ្ណៈ ចឹងកាលសមាហរណ៍កម្មហើយផ្លូវនេះក៏មិនទាន់មានស្រួលដែរ?

សុខាៈ បាទ!មានផ្លូវស្រួលដែលខ្ញុំទៅតាមផ្លូវនេះ ចេញចូលតាមផ្លូវទៅបាត់ដំបង ។

វណ្ណៈ តែឥឡូវមានផ្លូវហើយតែមិនមានភ្លើងតែពីរទៅបីឆ្នាំទៀតមានភ្លើងហើយ?

សុខាៈ បាទ!ឆ្នាំ២០១២មានភ្លើងដល់នេះ ។

វណ្ណៈ ព្រោះមានវារីអគ្គីសនី?

សុខាៈ បាទ!ពិបាកប្រើណាស់ភ្លើងនៅវាលវែង រាល់ថ្ងៃនេះប្រើម៉ាស៊ីនទឹកកកពីអូរកំបោរ ។

វណ្ណៈ បាទ ។

សុខាៈ មួយគីឡូ៣០០០រៀល ហើយថ្ងៃណាដាច់ៗ ។

វណ្ណៈ ចឹងតាំងពីនេះមកពូបានទៅលេងស្រុកកំណើតបានប៉ុន្មានដង?

សុខាៈ ទៅញឹកញាប់ណាស់ ខាតទៅមួយឆ្នាំ ដោយសារគ្រួសារឈឺខានទៅ ។

វណ្ណៈ ចឹងខែបុណ្យអីទៅដែរ?

សុខាៈ បាទ!ទៅបងប្អូនមានធុរៈមានរវល់អីទៅហើយ ទើបខានទៅមួយឆ្នាំដាង ។

វណ្ណៈ ចឹងពូគិតមើលកាលមុនយើងធ្លាប់ធ្វើសង្គ្រាមហើយមកដល់បច្ចុប្បន្នហ្នឹង តើមួយណាមានភាពធូរស្រាលជាង ចង់និយាយថាវាស្រួលចិត្តជាងអី?

សុខាៈ សង្គមនេះហើយស្រួលជាង ។

វណ្ណៈ ចឹងឥឡូវស្រួលជាងពីមុន?

សុខាៈ បាទ!កាលពីមុនវាសង្គ្រាមវាពិបាក ឥឡូវអត់មានសង្គ្រាមយើងដូរចិត្តយើងទៅណាក៏បានដើរហើយមានពីណាគ្រប់គ្រងអីយើងស្រួលហើយ ។

វណ្ណៈ បាទ ។

សុខាៈ ហើយការហូបចុកកាលដើរហើរអី យើងរកស៊ីអីតាមលទ្ធភាពយើងរកស៊ីបាន ។

វណ្ណៈ៖ ចឹងយើងរកបានប៉ុន្មានយើងហូបប៉ុណ្ណឹងទៅ?

សុខៈ ហូបប៉ុណ្ណឹងទៅ ។

វណ្ណៈ៖ តែបើយើងរកមិនបានយ៉ាប់ដែរ អ្នកខ្លះគ្នារកមិនបានគ្នាយ៉ាប់ដែរ?

សុខៈ យើងរកតាមលទ្ធភាពយើងរកបាន ។

វណ្ណៈ៖ និយាយទៅវាទីផ្សារសេរី?

សុខៈ បាទ! យើងចង់ហូបអីយើងមានហ្នឹង ជំនាន់មុនយើងវាអត់ចង់ហូបអីក៏វាមិនមានដែរ ។

វណ្ណៈ៖ បាទ ។

សុខៈ ដល់សង្គមនេះយើងចង់ហូបអីក៏មានដែរ យើងចង់ទៅណាក៏បានឲ្យតែយើងមានលុយមានកាក់ ។

វណ្ណៈ៖ ចឹងពូដូចថានៅជំនាន់ពូធ្វើការចឹង កាលហ្នឹងថ្មីត្បិតនៅខាងយោធាហ្នឹងដូចជាមិនមានការខ្វះខាតទេ ពូ?

សុខៈ បាទ ។

វណ្ណៈ៖ ចឹងពូមានបានដឹងថា តាមជនបទឬតាមស្រុកស្រែចំការមានការអត់អាហារសម្លាប់មនុស្សអីពូមានបានដឹងទេកាលហ្នឹង?

សុខៈ អត់ទេ ខ្ញុំនិយាយថ្ងៃស្អាហ្នឹងអត់មានបានដឹងទេ មិនបានដឹងថាគេយកមនុស្សទៅសម្លាប់នៅតាមតំបន់ផ្សេងៗ អត់បាយអត់អាហារអត់មានដឹងទេ ។

វណ្ណៈ៖ បាទ ។

សុខៈ អ្នកគ្រប់គ្រងនៅតាមតំបន់ខុសៗគ្នា នៅតាមកន្លែងខ្ញុំធម្មតាតែគ្រាន់តែវាមិនបានបរបូរ ។

វណ្ណៈ៖ បាទ ។

សុខៈ ពេលខែណាបាយយើងចែកគ្នាហូប ដូចថាមួយឆ្នាំងបួននាក់ទៅប្រាំប្រាំមួយនាក់ចឹងទៅយើងមានរបប ។

វណ្ណៈ៖ បាទ ។

សុខៈ ដូចថាឲ្យហូបបរបូរឲ្យឆ្អែតវាអត់ទេ គ្រាន់ថាវាល្មមកាលហ្នឹង ។

វណ្ណៈ៖ បាទ ។

សុខៈ តែខែណាខ្វះខាតហ្នឹង នៅពេលដែលអង្គការថាខ្វះខាតហ្នឹងយើងហូបដែលបបរមិនមួយកំប៉ុងបីបួនដបនាក់មួយខ្ទះ៥០ទៅ៦០នាក់ទេ អត់មានទេ បាយយើងដាំគ្រាន់តែជ្រាយដូចបបរ

ហ្នឹងណាស់ គ្រាន់តែប៉ុណ្ណឹងអន្តភាពខ្ញុំហ្នឹង តែអត់ហ្នឹងខ្លះមានលួចមានអីចឹងដែលហ្នឹង ហេវធ្វើការអស់កំលាំងមានលួចដកដំឡូងអីចឹងដែលហ្នឹង ។

វណ្ណៈ ចឹងពាក់ព័ន្ធនិងការអត់អាហារនិងយកមនុស្សទៅសម្លាប់ចឹង បើតាមគិត ពូគិតថាមកពីថ្នាក់ក្រោមធ្វើការខ្លះខ្លាយធ្វេសប្រហែសមិនធ្វើតាមថ្នាក់លើឬថ្នាក់លើហ្នឹងធ្វេសប្រហែលបណ្តែតបណ្តោយឲ្យមានការស្លាប់មនុស្សអីចឹងពូ តាមការយល់ឃើញ?

សុខា ថ្នាក់លើអត់មានមកបញ្ជា មកពីថ្នាក់ក្រោមៗមានការគុំនុំដូចជាអ្នកខ្លះថាមកពីអ្នកឯងដូចថាប្រជាជនដែលជម្លៀសមកពីភ្នំពេញមកចឹង ដោយសារតែពួក១៧មេសាហើយបានជាកូនចៅអញស្លាប់វាចឹងមានពុទ្ធិយាយចឹង ថាមកពីអាពួកមូលធននិយមពួកអាអ្នកមានបានកូនចៅស្លាប់មានចឹង មានគុំនំគ្នាចឹង ។

វណ្ណៈ បាទ ។

សុខា បើថាឲ្យមានបញ្ជាពីលើទៅសម្លាប់អត់មានទេ ជំនាន់ហ្នឹងមានការគុំនំគ្នាហ្នឹង មានការគុំនំតៗគ្នាមក ។

វណ្ណៈ បាទ ។

សុខា ខ្ញុំបងប្អូនខាងពុកម្តាយខ្ញុំទាំងអស់សុទ្ធតែរងការសម្លាប់ជំនាន់ប៉ុល ពតទាំងអស់ ។

វណ្ណៈ ចឹងពូមានសាច់ញាតិស្លាប់ជំនាន់ហ្នឹងដែរ?

សុខា ស្លាប់ប៉ាខ្ញុំ ពូខ្ញុំ អ៊ំខ្ញុំស្លាប់ជំនាន់ហ្នឹង មិនមែនថាអូអ្នកតស៊ូធ្វើកងទ័ពហើយអត់មានបងប្អូនស្លាប់គេយកទៅសម្លាប់ចោលដូចគ្នាហ្នឹងជំនាន់ហ្នឹង ចុះកាលហ្នឹងមាននៅមូលគ្នាទេ នៅផ្សេងគ្នានៅនោះខ្លះនៅទីខ្លះកាលហ្នឹង អត់មានជួបគ្នាទេ ។

វណ្ណៈ បាទ ។

សុខា អត់មានការជួបគ្នាឬមានសរសេរសំបុត្រឆ្លើយឆ្លងគ្នាគឺអត់មានទេ ។

វណ្ណៈ បាទ ។

សុខា នៅកន្លែងអន្តភាពណានៅហ្នឹងទៅ នៅតំបន់ណានៅហ្នឹងទៅ ដឹងថាព្រលឹមឡើងចេញធ្វើការទៅ គេឲ្យឈប់ៗទៅគេឲ្យធ្វើការៗទៅដល់ពេលយប់ធ្វើការមួយម៉ោងពីរម៉ោងនៅតាមអន្តភាពហ្នឹង ។

វណ្ណៈ បាទ ។

សុខា នៅពេលសម្រាកមានយាមទៀតជំនាន់ហ្នឹង ថ្ងៃត្បិតអត់មានកាំភ្លើងតែមានយាមនៅកន្លែងយាមហ្នឹង ជំនាន់ហ្នឹងជួបការលំបាកក៏ជួបតែ តែមិនដឹងជាធ្វើម៉េចជំនាន់ហ្នឹង ។

វណ្ណៈ	បាទ ។

សុខាៈ	មិនដូចជាឥឡូវណាកន្លែងធូរស្រាលកន្លែងអត់ឃ្លានខ្លាំងវាចឹងមានដោយកន្លែង ។

វណ្ណៈ	ចឹងក្រោយៗមកពូមានតាមដានតុលាការកាត់ទោសអីខ្លះៗដែលពូ?

សុខាៈ	អត់ដែលបានតាមដាន ខ្ញុំនិយាយតាមត្រង់អត់ដែលបានគិតគូរផងទេ រឿងច្បាប់អីចឹង សព្វថ្ងៃគិតរឿងធ្វើការខ្លួនឯង មិនដែលបានស្តាប់យកចិត្តទុកដាក់ទេ ណាមួយមិនដែលមានវិទ្យុផង ។

វណ្ណៈ	ចឹងពូមានបានដឹងថា មេដឹកនាំមួយចំនួនត្រូវបានគេឃុំខ្លួនឬមួយពូមិនបានដឹងទេ?

សុខាៈ	អត់ដឹង ។

វណ្ណៈ	ចឹងខ្ញុំប្រាប់ពូទៅ ដូចជារាល់ថ្ងៃនេះ ឌុចត្រូវបានកាត់ទោសហើយប៉ុន្តែគាត់បានប្តឹងទៅខទណ៍មិនទាន់ចេញសាលក្រមម្តងទៀត លើកមុនគេបានចេញសាលក្រមហើយកាត់ទោសគាត់ឲ្យជាប់គុក៣៥ឆ្នាំ តែទូទាត់ទៅសល់តែជាង១០ឆ្នាំអីចឹង ហើយខាងមេធាវីរបស់ឌុចហ្នឹងប្តឹងតវ៉ាប្តឹងខទណ៍សុំឲ្យកូនក្តីគាត់រួចខ្លួន ចឹងគេត្រូវសម្រេចក្តីខទណ៍ហ្នឹងមួយសារទៀតចឹងនៅតែថ្ងៃចេញសាលក្រម ចឹងនៅសល់មេដឹកនាំបួននាក់ទៀត ដូចជាតា នួន ជា តា ខៀវ សំផន តា អៀង សារីនិងអៀង ធិរិទ្ធសព្វថ្ងៃពួកគាត់ត្រូវបានឃុំខ្លួននៅតុលាការកាត់ទោសខ្មែរក្រហម ពូគិតថាការឃុំខ្លួនគាត់ដើម្បីកាត់ទោសរកយុត្តិធម៌ជូនប្រជាជនដែលបានស្លាប់ទៅជាងមួយលានហ្នឹងជាការត្រឹមត្រូវ ឬមួយគិតថាតុលាការដែលធ្វើហ្នឹងវាមិនយុត្តិធ៌ទេសម្រាប់គាត់អីចឹង ចឹងពូយល់យ៉ាងម៉េចដែរ?

សុខាៈ	តាមការវិភាគរបស់ខ្ញុំអង្គការរដ្ឋធ្វើនេះ តាមច្បាប់ត្រឹមត្រូវ តែខ្ញុំគិតថាមិនត្រឹមត្រូវព្រោះនេះមិនមែនបញ្ហាពីគាត់ជាអ្នកសម្លាប់ណា មានតៗគ្នាមិនចឹង ។

វណ្ណៈ	បាទ!តែនេះគេគិតថា ចេះគេគិតថា មេដឹកនាំកំពូលខបមាថាជាម៉ែជាឪបណ្តោយឲ្យកូនចៅស្លាប់ច្រើន ចឹងបើតាមច្បាប់អន្តរជាតិហ្នឹងគេសំដៅទៅលើមេដឹកនាំធំ ។

សុខាៈ	បាទ ។

វណ្ណៈ	ឥឡូវឧបមាថា នៅក្នុងសម័យសម្តេចហ៊ុន សែននេះ ឧទាហរណ៍បើសិនជាគាត់បន្ទត់បាយមនុស្ស គាត់ធ្វើឲ្យមនុស្សស្លាប់ច្រើន មិនមែនគាត់ជាអ្នកមកសម្លាប់ទេ តែគេចាត់ទុកគាត់ជាមេថ្នាក់ដឹកនាំ ចឹងទោះបីគាត់មិនបានសម្លាប់ខ្លួនឯងក៏ដោយតែអ្នកក្រោមសម្លាប់មានន័យថាគាត់ធ្វើជាមិនឃើញមិនឮ ចឹងប្រទេសយើងបានចូលក្នុងអង្គការសហប្រជាជាតិហើយអង្គការសហប្រជាជាតិគេដោតសំខាន់ទៅលើសិទ្ធមនុស្ស ដូចជាការរំលោភមនុស្សឬប្រើ

អំពើហឹង្សាផ្សេងៗ ចឹងហើយបានជាគេបង្កើតតុលាការអន្តរជាតិ ចឹងរាល់ថ្ងៃនេះមិនមែនជាតុលាការខ្មែរយើងសុទ្ធទេ តុលាការខ្មែរយើងបានចូលរួមជាមួយតុលាការអង្គការសហប្រជាជាតិ«យូអ៊ិន»ចឹងអន្តរជាតិគេមកកាត់ទោសមេដឹកនាំខ្មែរក្រហម ហើយនៅក្នុងសង្គមណាមួយក៏ដោយបើសិនជាមេដឹកនាំធ្វើឲ្យស្លាប់ប្រជាជនខ្លួនឯងច្រើនគេត្រូវតែកាត់ទោស ។

សុខាៈ បាទ ។

វណ្ណៈ មិនថាគាត់ចាស់ហើយមិនត្រូវកាត់ទោសទេ អាហ្នឹងគ្រាន់តែជាសារមួយសម្រាប់ អាហ្នឹងយើងគិតថា គាត់ចាស់ហើយមិនត្រូវកាត់ទោសគាត់ចឹង តែច្បាប់គេមិនគិតចឹងទេ ច្បាប់គេគិតថាអ្នកណាធ្វើខុសអ្នកហ្នឹងត្រូវទទួល ចឹងបើសិនជាគាត់អត់មានខុសទេ គាត់មានសិទ្ធតតាំងចំពោះមុខច្បាប់ថា ខ្ញុំមិនបានខុសខ្ញុំអត់មានពាក់ព័ន្ធអាហ្នឹងគេវិនិច្ឆ័យទៅតាមហ្នឹង ។

សុខាៈ បាទ ។

វណ្ណៈ តែឥឡូវយើងមិនចាត់ទុកគាត់ជាអ្នកសម្លាប់មនុស្សទេ គាត់គ្រាន់តែជាជនសង្ស័យទេសព្វថ្ងៃនេះណាស់ ចឹងនៅសល់ប៉ុន្មានខែខាងមុខនេះគេចាប់ផ្ដើមកាត់ទោសហើយ ចឹងយើងបានដឹងទាំងអស់គ្នាថា គាត់ខុសឬមិនខុសនៅពេលនោះ ចឹងបើតាមយោបល់ពូថាវាមិនយុត្តិធ៌ទេកាត់ទោសអ្នកទាំងអស់ហ្នឹង?

សុខាៈ បាទ ។

វណ្ណៈ បាទ!នេះជាគំនិតរបស់ពូវាអត់មានបញ្ហាអីទេ គំនិតប្រជាជនមានផ្សេងៗគ្នា ខ្លះគេថាកាត់ទោសហ្នឹងត្រឹមត្រូវ ខ្លះថាកាត់ទោសហ្នឹងវាមិនត្រឹមត្រូវទេ វាមិនយុត្តិធម៌ទេ ខ្លះថាកាត់ទោសទៅដើម្បីព្រមានអ្នកក្រោយកុំឲ្យធ្វើផ្ដេះផ្ដាស់ទៀត អាហ្នឹងគ្រាន់ជាចឹងទេ ចឹងពូមានអីចង់និយាយបន្ថែមទៀតទេ?

សុខាៈ អត់មានអីទេ ។

វណ្ណៈ ចឹងខ្ញុំអរគុណពូច្រើន ។

សុខាៈ បាទ ។

**ចប់**